## មេរៀនសង្ខេប

- ធ្នូលជាកោសិកាដែលចាប់យករំញោចពីមជ្ឈដ្ឋានជុំវិញ។សរីរាង្គវិញ្ញាណបំប្លែងថាមពលនៃរំញោចឱ្យទៅជាថាមពលនៃអាំងភ្លុចប្រសាទ ។ ខួរក្បាលជាអ្នកបកប្រែរំញោច មិនមែន សរីរាង្គវិញ្ញាណទេ ។
- គ្រាប់ភ្នែកមនុស្សមានភ្នាសបីស្រទាប់គឺ ស្លេរ៉ូទិច កូរ៉ូអ៊ីត រេទីននិងមជ្ឈដ្ឋានថ្លាស្រោបដោយភ្នាសទាំងនេះ។ស្រទាប់រេទីនមានកោសិការួសនិងពន្លឺពីរប្រភេទគឺ កោសិកាកោននិង កោសិកាដំបង ។កោសិកាដំបងរួសនិងពន្លឺខ្សោយហើយវាចាប់យកចលនាតែមិនចាប់យកពណ៌ទេ ។ កោសិកាកោនរួសនឹងពណ៌ដោយត្រូវការពន្លឺខ្លាំង។ ភ្នែកផ្លាស់ពន្លឺទៅជាអាំងភ្លុចប្រសាទដែលដឹកនាំតាមសរសៃប្រសាទអុបទិចទៅកាន់ខួរក្បាល។ខួរក្បាលជាអ្នកបកប្រែអាំងភ្លុចប្រសាទឱ្យទៅជាគំហើញ ។
- ត្រចៀកមានបីផ្នែកគឺ ត្រចៀកក្រៅ ត្រចៀកកណ្ដាល និងត្រចៀកក្នុង ។ ល្បីកើតឡើងនៅ ពេលរលកសូរធ្វើដំណើរទៅកាន់ត្រចៀកក្នុង ដែលនៅទីនោះចាប់ផ្ដើមកើតមានអាំងភ្លុចប្រសាទ ។ អាំងភ្លុចប្រសាទធ្វើដំណើរទៅកាន់ខួរក្បាលតាមសរសៃប្រសាទសោតវិញ្ញាណ ។ ត្រចៀកក្នុងនិងខួរតូចមាននាទីក្នុងតំហែរក្សាលំនឹង ។
- ពន្លកជិវ្ហាវិញ្ញាណជាធ្នូលវិញ្ញាណដែលរួសនឹងរសជាតិ។កោសិកាទាំងនេះស្ថិតនៅក្នុងអញ្ចាញលើផ្ទៃអណ្ដាត។អណ្ដាតរួសនឹងរសជាតិមូលដ្ឋានបួនគឺ ជូរ ល្វីង ប្រៃ និង ផ្អែម ។ កោសិកាឃានវិញ្ញាណជាចូលវិញ្ញាណរួសនឹងក្លិនដែលស្ថិតនៅក្នុងភ្នាសសើមនៃ ប្រហោងច្រមុះ ។ ធ្នូលវិញ្ញាណទាំងពីរបែបនេះរួសនឹងសារធាតុគីមីក្នុងទឹកនិងខ្យល់ ។
- ក្នុងស្រទាប់ខែមរបស់ស្បែកមានធ្នូលវិញ្ញាណច្រើនបែប ។ ពេលទទួលបានរំញោច ធ្នូលវិញ្ញាណខ្លះរួសនឹងបំណះទង្គិចស្រាល ខ្លះទៀតរួសនឹងបំណះទង្គិចខ្លាំង ។ ធ្នូលវិញ្ញាណដទៃ ទៀតមាននាទីទទួលការឈឺចាប់ កម្ដៅ និងភាពត្រជាក់ ។